# មេរោគ E.coli នៅក្នុងភ្ពីរ

Possible Source of E.coli Outbreak Identified

ក្រសួងរដ្ឋាភិបាលទទួលបន្ទុកផ្នែកខាងចំណីអាហារនិងឧសថ, Food and Drug Administration បានផ្តល់ ដំណឹងកាលពីថ្ងៃសៅរ៍ទី 16 ខែ កញ្ញា ឆ្នាំ 2006 កន្លងមកនេះ ថាប្រភពនៃភ្ពីរដែលមានមេរោគ E. coli អាចចេញពីក្រុមហ៊ុនផលិតបន្លែនៅ រដ្ឋកាលីហ្វរនី ហើយដែលធ្វើឲ្យមនុស្សស្លាប់បាត់បង់ជីវិតចំនួនមួយនាក់ និងធ្លាក់ខ្លួនចំនួន 94 នាក់។

ក្រសួងរដ្ឋាភិបាលផ្នែកចំណីអាហារនិងឧសថ បានអំពាវនាវ កុំឲ្យប្រជាជនទទួលទានភ្ពី ដែលដាក់លក់នៅក្នុងកញ្ចប់ថងផ្លាស្ទិក។ ហើយថា ទោះបីជា លោកអ្នកលាងភ្ពីរទាំងនោះក៏ដោយ ក៏វាពុំមានប្រយោជន៍ដែរ ពីព្រោះមេរោគបាក់តេរីនេះ នៅជាប់ស្អិតនឹងបន្លែនេះ។ ដូច្នេះ ប្រសិនបើ លោកអ្នកទិញភ្ពីរ នៅក្នុងរយៈពេល មួយអាទិត្យកន្លងមកនេះ គួរចោលវា ហើយកុំឲ្យទិញទៀត រហូតដល់ពេលណាដែលអាញ្ញាធរ ប្រកាស់ថា វាលែងមានមេរោគ E. coli នេះតទៅទៀតហើយ។ បន្លែ ភ្ពីរ , Spinach ក្នុងកញ្ចប់ដែលមានប្រឡាក់មេរោគនេះ គឺ មានសរសេរដាក់ថា ភ្ពីរមានគុណភាពល្អ ប្រសិនបើ ប្រើចន្លោះពេលពី ថ្ងៃទី 17 ខែសីហា ទល់ ថ្ងៃទី 1 ខែ តុលា ឆ្នាំ 2006។

មេរោគ E. coli នៅក្នុងភ្ពីរ បានចាប់ផ្តើមរាតត្បាតកាលពីថ្ងៃព្រហស្បត្តិ ទី 14 កន្លងមកនេះ ក្នុងចំណោម 8 រដ្ឋ ហើយ ឥឡូវនេះឡើងដល់ទៅ 20 រដ្ឋ ។ រដ្ឋទាំងនេះ មាន ដូចជា៖ រដ្ឋ California, Connecticut, Idaho, Indiana, Kentucky, Maine, Michigan, Minnesota, Nevada, New Mexico, New York, Ohio, Oregon, Pennsylvania, Tennessee, Utah, Virginia, Washington, Wisconsin, និង Wyoming ។ ដូច្នេះ ប្រសិន បើលោកអ្នកមានបងប្អូនឬញាតិមិត្ត រស់នៅក្នុងរដ្ឋទាំងប៉ុន្មាន ដែលខ្ញុំបាទបានជំរាបមកនេះ សូមមេត្តាផ្តល់ដំណឹងនេះ ទៅឲ្យគាត់ឲ្យបានជ្រាបផង។

មេរោគ E. coli អាចធ្វើឲ្យអ្នកជម្ងឺចាប់ រាគរុះ ហើយជួនកាលមានឈាមក្នុងលាមកផង។ មនុស្សពេញវ័យ ភាគច្រើន អាចជាសះស្បើយទៅវិញបាន ក្នុងរយៈពេលមួយអាទិត្យ។ តែមានអ្នកខ្លះទៀត ជាពិសេស ក្មេងតូចៗនិងអស់លោកចាស់ទុំ មេរោគ E. coli អាចធ្វើទុក្ខរហូតដល់ខូចតម្រងនោម ឬស្លាប់បាត់បង់ជីវិតក៏មាន។

អ្នកដែលធ្លាក់ខ្លួនឈឺ ដោយសារទទួលទានភ្ពីរនៅក្នុងកញ្ចប់ផ្លាស្ទិក គួរទាក់ទងទៅគ្រូពេទ្យរបស់ខ្លួនជាបន្ទាន់។

យោលទៅតាម មជ្ឈមណ្ឌលការពារនិងបង្ក្រាបជម្ងឺ, Center for Disease Control and Prevention បានឲ្យដឹងថា មេរោគ E. coli ច្រើនមាននៅក្នុងពោះវៀនគោ និងសត្វដទៃទៀត ហើយអ្នកជម្ងឺច្រើន ធ្លាក់ខ្លួនឈឺ ដោយសារការប៉ះពាល់នឹងលាមករបស់សត្វទាំងនោះ។ យោលទៅតាមស្ថិតិ នៅក្នុងសហរដ្ឋ មានមនុស្សធ្លាក់ខ្លួនឈឺដោយសារ មេរោគបាក់តេរីប្រភេទនេះ ចំនួនប្រហែលជា 7 ម៉ឺន 3 ពាន់ក្នុងមួយឆ្នាំៗ រួមទាំងមានមនុស្សស្លាប់ចំនួន 61 នាក់ផង។

ប្រភពនៃមេរោគ E. coli ច្រើនមាននៅតាមចំណីអាហារដែលចំអិនពុំបានឆ្អិនល្អ , ទឹកដោះគោឆៅ, ទឹកផ្លែឈើដែលពុំចំអិន, ទឹកឬសាច់ដែលប្រឡាក់ឬជាមួយសាច់មានមេរោគ E. coli ជាពិសេស សាច់ Hamburger ដែលចំអិនពុំបានឆ្អិនល្អ។

ចំពោះពត៌មានបន្ថែមស្ដីអំពីការរាតត្បាតនៃ មេរោគ E. coli សូមមេត្តាអានវិបសៃរបស់ក្រសួងរដ្ឋាភិបាលផ្នែកចំណីអាហារនិងឧសថ ដែលហៅថា U.S. Food and Drug Administration ដែលមានអាស័យដ្ឋាន www.fda..gov ឬទូរស័ព្ទលេខ 1-888-463-6332 ឬ មជ្ឈមណ្ឌលការពារនិងបង្ក្រាបជម្ងឺ, Center for Disease Control and Prevention ដែលមានអាស័យដ្ឋា www.cdc.gov ។

*អត្ថបទនេះដកស្រង់និងបកប្រែចេញពីសារពត៌មាន Healthfinder នៃ ក្រសួងសុខភាព និងមនុស្សធម៌ U.S. Department of Health and Human Services។ ដោយ មណ្ឌលមេត្តា សុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល។*

http://www.healthfinder.gov/news/newsstory.asp?Docid=534995